## ២.១១ ពង្រឹងប្រព័ន្ធពិនិត្យតាមដាន

### វត្ថុបំណង និង យុត្តិកម្ម

កម្មវិធីពង្រឹងប្រព័ន្ធពិនិត្យតាមដាន មានវត្ថុបំណង ២ សំខាន់គឺ ១) កែលំអការពិនិត្យតាមដានបច្ចេកទេស និង ហិរញ្ញវត្ថុនៅគ្រប់កំរិត សម្រាប់ពង្រឹងការអភិវឌ្ឍ ការគ្រប់គ្រង និងវាយតម្លៃគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធី ។ ការពិនិត្យតាមដានផលប៉ះពាល់ និងការបំពេញការងារវិស័យអប់រំត្រូវពង្រឹងតាមរយៈ ២) ពង្រឹងស្តង់ដាធានាគុណភាព ប្រសិទ្ធភាពវិស័យអប់រំ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ ។

ការពង្រឹងសមត្ថភាពសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ គណនេយ្យ និងសវនកម្ម ឱ្យស្របទៅនឹងបរិបទនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានសារៈប្រយោជន៍ណាស់សម្រាប់កែលំអប្រសិទ្ធភាព និងការបំពេញការងារវិស័យអប់រំ ។ វត្ថុបំណងគន្លឹះមួយទៀតគឺ ពង្រឹងគ្រប់ទិដ្ឋភាពនៃការពិនិត្យតាមដាន និងវាយតម្លៃការបំពេញការងារវិស័យអប់រំប្រកបដោយតម្លាភាព និងគណនេយ្យភាព តាមរយៈការលើកកំពស់ស្តង់ដាប្រសិទ្ធភាព និងគុណភាពអប់រំ និងការចូលរួមរបស់អ្នកពាក់ព័ន្ធនានានៅក្នុងដំណើរការកែទម្រង់វិស័យអប់រំ ។

### អាំងឌីកាទ័រ និង ចំណុចដៅចម្បងៗ

- មន្ត្រី BMCs ទាំងអស់នឹងមានប្រព័ន្ធព័ត៌មានគ្រប់គ្រងផ្អែកលើ ICT ត្រឹមឆ្នាំ ២០០៨ ។
- BMCs ទាំងអស់ នឹងត្រូវបានបំប៉នពីកិច្ចបញ្ជិការគណនេយ្យ ត្រឹមឆ្នាំ ២០០៩ ។
- BMCs ១០០% និងសាលារៀន/គ្រឹះស្ថានសិក្សា ២០% ត្រូវបានធ្វើសវនកម្មប្រចាំឆ្នាំ ដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រឹមឆ្នាំ ២០១០ ។
- អត្រាដកសាច់ប្រាក់សម្រាប់កម្មវិធីសកម្មភាពជាអាទិភាពអោយបាន ១០០% ចាប់ពីឆ្នាំ ២០០៧ ទៅ ។
- ធ្វើអង្កេតផលប៉ះពាល់នៃកម្មវិធីសកម្មភាពជាអាទិភាព នៅចុងឆ្នាំ ២០០៧ ។
- ផលិតសៀវភៅស្ថិតិ និងអាំងឌីកាទ័រអប់រំ/ប័ណ្ណផ្ទត់/សៀវភៅព័ត៌មានអប់រំប្រចាំឆ្នាំ ។
- របាយការណ៍បំពេញការងារវិស័យអប់រំ ត្រូវបានរៀបចំរៀងរាល់ឆ្នាំ ។

### យុទ្ធសាស្ត្រ និង វិសាលភាព

កម្មវិធីនេះនឹងពង្រឹងក្រុមការងារពិនិត្យតាមដាន ថ្នាក់ខេត្ត-ក្រុង និង ថ្នាក់ស្រុក-ខ័ណ្ឌបន្ថែមទៀត ដោយផ្ទេរសិទ្ធអំណាច និងការទទួលខុសត្រូវច្បាស់លាស់ សម្រាប់កម្មវិធីសកម្មភាពជាអាទិភាពនីមួយៗ ឬ ចង្កោម កម្មវិធីសកម្មភាពជាអាទិភាព ។ ទិដ្ឋភាពសំខាន់នៃកម្មវិធីនេះ គឺការធ្វើទស្សនះកិច្ចជាទៀងទាត់នៅតាមអង្គភាព គ្រប់គ្រងថវិកា និង គ្រឹះស្ថានសិក្សា សាលារៀន ស្របតាមចំណុចដៅដែលបានឯកភាព និងការធ្វើរបាយការណ៍ ហិរញ្ញវត្ថុ និងបច្ចេកទេសទាន់ពេលវេលារបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង

ជូនទៅថ្នាក់កណ្តាល ស្របទៅតាមកាលវិភាគប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆ្នាំ។ កម្មវិធីនេះនឹងជួយគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធបន្ថែមទៀត ដែលរួមមានសេចក្តីណែនាំស្តីពីការពិនិត្យតាមដាន និងការធ្វើរបាយការណ៍នៅក៏រិតផ្សេងៗរបស់ប្រព័ន្ធអប់រំ ។

អាទិភាពគន្លឹះមួយគឺ បង្កើនវិសាលភាព និង គុណភាពនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ និងដៃគូនៅក្នុងការពិនិត្យតាមដាន ដើម្បីកែលំអតម្លាភាព និងគណនេយ្យភាព ។ ប្រការនេះរួមមានការពង្រឹងបន្ថែមទៀតដំណើរការពិនិត្យឡើងវិញរួមគ្នានៃការបំពេញការងារប្រចាំឆ្នាំ ការប្រើប្រាស់សវនកម្មខាងក្រៅ តាមរយៈអាជ្ញាធរជាតិសវនកម្ម និង ស្វែងរកការចូលរួមពីក្រុមប្រឹក្សាឃុំ-សង្កាត់ ឬគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ-សង្កាត់ និង លេខាធិការដ្ឋានអោយបានខ្លាំងក្លា និងមានប្រសិទ្ធភាព ពិសេសផ្តោតទៅលើការពង្រីក និង ពង្រឹងតួនាទីរបស់គេ ជួយដល់ការរៀបចំផែនការ ការពិនិត្យតាមដានបច្ចេកទេស និង ហិរញ្ញវត្ថុ នៅថ្នាក់សាលារៀន។

## សេចក្តីសង្ខេបសកម្មភាពចម្បងៗ

- កែលំអការប្រមូលទិន្នន័យ ការវិភាគ និងការពិនិត្យតាមដាន BMC នៅថ្នាក់កណ្តាល រួមមាននាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានផែនការ នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអធិការដ្ឋានអប់រំ ព្រមទាំង BMC នៅក្នុង ២៤ ខេត្ត-ក្រុង និង ១៨៥ ស្រុក-ខ័ណ្ឌ ។
- ពង្រឹងការពិនិត្យតាមដានហិរញ្ញវត្ថុនៅគ្រប់ក៏រិតថ្នាក់ ។ នាយកដ្ឋានហិរញ្ញវត្ថុ ដើរតួសំខាន់នៅក្នុងការពិនិត្យតាមដាននេះ ។(សូមមើលតម្រូវការកសាងសមត្ថភាពលំអិតខាងក្រោម) ។
- ពង្រឹងនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងនីតិវិធីការងារ (សូមមើលតម្រូវការកសាងសមត្ថភាពលំអិតខាងក្រោម) ។
- ពង្រឹងការពិនិត្យតាមដានផលប៉ះពាល់ ។ សកម្មភាពសំខាន់ៗរួមមាន ការអភិវឌ្ឍយុទ្ធសាស្ត្រ និងអាទិភាពនានាសម្រាប់ការស្រាវជ្រាវប្រតិបត្តិ ការអភិវឌ្ឍយុទ្ធសាស្ត្រ និងកម្មវិធីពិនិត្យតាមដាននៅថ្នាក់ស្រុក-ខ័ណ្ឌ/សហគមន៍ ព្រមទាំងសកម្មភាពកសាងសមត្ថភាព ។
- *ពង្រឹងសវនកម្ម និងការពិនិត្យតាមដានគុណភាព និង ស្តង់ដា :* សកម្មភាពសំខាន់ៗ រួមមាន ក) ការពិនិត្យតាមដានជាគំរូតាង (Sample monitoring) លើការបំពេញការងារទូទៅរបស់សាលារៀន ខ) ការវាយតម្លៃជាគំរូតាងលើការបំពេញការងាររបស់អ្នកគ្រប់គ្រង និង គ្រូបង្រៀន គ) ការពិនិត្យឡើងវិញជាគំរូតាងលើសកម្មភាពបង្រៀន និង រៀន ។ ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំក្របខ័ណ្ឌការងារសមស្របមួយ ដែលរួមមានការកំណត់អាំងឌីកាទ័រគុណភាព និង វិធានការសម្រាប់ផ្ទៀងផ្ទាត់ ។

## ការរៀបចំការគ្រប់គ្រង និង ការពិនិត្យតាមដាន

អង្គភាពគ្រប់គ្រងថវិការបស់នាយកដ្ឋានហិរញ្ញវត្ថុ ទទួលខុសត្រូវលើការពិនិត្យតាមដានផ្នែកហិរញ្ញវត្ថុ ។ ប្រធាននាយកដ្ឋានដែលជាប្រធានអង្គភាពគ្រប់គ្រងថវិកា ទទួលខុសត្រូវលើការធ្វើផែនការ និងការអនុវត្តការងារពិនិត្យតាមដាន និងសម្របសម្រួលក្រុមការងារគ្រប់គ្រងហិរញ្ញវត្ថុ ។ មូលនិធិត្រូវបានផ្ទេរទៅឱ្យអង្គភាពគ្រប់គ្រងថវិកា ខេត្ត-ក្រុង សម្រាប់សកម្មភាពពិនិត្យតាមដាន ។

អង្គភាពគ្រប់គ្រងថវិការបស់អធិការដ្ឋានអប់រំ ទទួលខុសត្រូវលើការបំពេញការងារវិស័យ រួមមានសមាសភាគពិនិត្យតាមដាន និងវាយតម្លៃផ្នែកគុណភាព ។

អង្គភាពគ្រប់គ្រងថវិការបស់នាយកដ្ឋានផែនការ ទទួលខុសត្រូវលើការពិនិត្យតាមដានផលប៉ះពាល់ ដែលរួមមាន ការបំពេញការងារអប់រំផ្នែកបរិមាណ និងការសិក្សាស្រាវជ្រាវប្រតិបត្តិ ។ ការទទួលខុសត្រូវដ៏ទូលំទូលាយរបស់ក្រុមពិនិត្យតាមដាននៅថ្នាក់ខេត្ត-ក្រុង ដឹកនាំដោយប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ត្រូវធានាថា ផែនការការងារ និងរបាយការណ៍ពិនិត្យតាមដាន ស្របគ្នាជាមួយនឹងសេចក្តីណែនាំ និងចំណុចដៅដែលបានឯកភាព ហើយផ្ញើជូនមកថ្នាក់កណ្តាល ដោយអនុលោមតាមកាលវិភាគដែលបានព្រមព្រៀងគ្នា ។

ក្រសួងអប់រំ យុវជន និង កីឡា នឹងបែងចែកមូលនិធិសម្រាប់ដំណើរការសវនកម្មផ្ទៃក្នុង តាមរយៈ ពំជរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ។ ការធ្វើរបាយការណ៍សវនកម្ម នឹងត្រូវបង្ហាញជូនដល់នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងអប់រំ យុវជន និង កីឡា ដែលជាមូលដ្ឋានមួយសម្រាប់ធ្វើសកម្មភាពសមស្រប ។

អង្គភាពគ្រប់គ្រងថវិការបស់អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ទទួលខុសត្រូវលើការត្រួតពិនិត្យដំណើរការទូទៅនៃប្រព័ន្ធគ្រប់គ្រង និងដំណើរប្រព្រឹត្តជាទូទៅនៃស្ថាប័ន និងគ្រឹះស្ថានសិក្សាទាំងឡាយ លើផ្នែកគ្រប់គ្រងបុគ្គលិក ទំនាក់ទំនង គ្រប់គ្រងរដ្ឋបាល ផែនការ គ្រប់គ្រងហិរញ្ញវត្ថុ បរិក្ខារ និងទ្រព្យសម្បត្តិរដ្ឋ ។ ក្រសួងអប់រំ យុវជន និង កីឡា នឹងបែងចែកមូលនិធិសម្រាប់ដំណើរត្រួតពិនិត្យដំណើរការទូទៅនៃប្រព័ន្ធគ្រប់គ្រង និងដំណើរប្រព្រឹត្តជាទូទៅនៃស្ថាប័ន និងគ្រឹះស្ថានសិក្សាទាំងឡាយតាមរយៈ BMC របស់អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ។ ការធ្វើរបាយការណ៍អធិការកិច្ច នឹងត្រូវបង្ហាញជូនដល់អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលជាមូលដ្ឋានសម្រាប់ធ្វើសកម្មភាពសមស្រប ។

## ផែនការហិរញ្ញវត្ថុ

ផែនការហិរញ្ញវត្ថុ បានផ្តល់អាទិភាពចំពោះការពង្រីក និងពង្រឹងការងារសវនកម្ម ការងារអធិការកិច្ច និងការពិនិត្យតាមដានផ្នែកហិរញ្ញវត្ថុ ។ ការបែងចែកថវិកាដោយឡែកៗ ត្រូវបានរៀបចំសម្រាប់ថ្នាក់ខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ ដោយពិចារណាទៅលើចំនួនស្រុក-ខ័ណ្ឌ សាលារៀន និងអង្គភាពគ្រប់គ្រងថវិកាដែលមាននៅក្នុងខេត្ត-ក្រុងនីមួយៗ ។ ផែនការហិរញ្ញវត្ថុនេះ ក៏គ្របដណ្តប់លើវិសាលភាពនៃការពិនិត្យតាមដានគុណភាពអប់រំផងដែរ ។

**តារាងទី ១១ : ផែនការហិរញ្ញវត្ថុសម្រាប់ការពង្រឹងប្រព័ន្ធពិនិត្យតាមដាន**

| សកម្មភាព | ចំណាយគិតជាលានរៀល | | | | |
|---|---|---|---|---|---|
| | 2006 | 2007 | 2008 | 2009 | 2010 |
| ក-ពង្រឹងការពិនិត្យតាមដានហិរញ្ញវត្ថុ | 5,400 | 3,000 | 1,600 | 1,600 | 2,100 |
| ខ-ពង្រឹងការពិនិត្យតាមដានការបំពេញការងារវិស័យ | 400 | 500 | 500 | 500 | 500 |
| គ- ពង្រឹងការពិនិត្យតាមដានផលប៉ះពាល់ | 500 | 500 | 500 | 500 | 500 |
| ឃ- ពង្រឹងសវនកម្មផ្ទៃក្នុង | 1000 | 800 | 500 | 500 | 625 |
| ង- ពង្រឹងការងារអធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ | 600 | 500 | 300 | 300 | 375 |
| **ធនធានសរុប** | **7,900** | **5,300** | **3,400** | **3,400** | **4,100** |

**តម្រូវការកសាងសមត្ថភាព**

- ពង្រឹងសមត្ថភាពនាយកដ្ឋានហិរញ្ញវត្ថុ ដើម្បីពិនិត្យតាមដាន និងធ្វើរបាយការណ៍ស្តីពីការបញ្ចេញ និងលំហូរថវិការបស់កម្មវិធីសកម្មភាពជាអាទិភាពនានា តាមរយៈរតនាគារជាតិ ខេត្ត-ក្រុង អង្គភាពគ្រប់គ្រងថវិកា និងគ្រឹះស្ថានសិក្សា សាលារៀន ។
- ពង្រឹងប្រព័ន្ធសន្តិសុខហិរញ្ញវត្ថុនៅគ្រប់កំរិត ជាពិសេសនៅថ្នាក់ ខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ ដែលរួមមានការប្រើប្រាស់ប្រព័ន្ធធនាគារខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ។
- ពង្រឹងសមត្ថភាពមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង និងការិយាល័យអប់រំ យុវជន និង កីឡា ស្រុក-ខ័ណ្ឌ ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេសជាប្រចាំដល់អង្គភាពគ្រប់គ្រងថវិកា និងសាលារៀន ដើម្បីធានាសកម្មភាពការចំណាយ និងការធ្វើរបាយការណ៍ទាន់ពេលវេលា ។
- បំប៉នបុគ្គលិកពីការអភិវឌ្ឍប្រព័ន្ធគណនេយ្យ ដែលរួមមានភាពស្របគ្នាទៅនឹងបទដ្ឋានថ្មី ដែលកើតចេញពីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- ពង្រឹងសមត្ថភាពមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង និងការិយាល័យអប់រំ យុវជន និង កីឡា ស្រុក-ខ័ណ្ឌ ក្នុងការអនុវត្តការប្រមូល និងវិភាគទិន្នន័យ ការពិនិត្យតាមដានការរីកចម្រើន និងការធ្វើរបាយការណ៍ ស្តីពីកម្មវិធីសកម្មភាពជាអាទិភាពនានា ។
- ពង្រីក និង ពង្រឹងសមត្ថភាពសវនកម្មនៅថ្នាក់កណ្តាល និងថ្នាក់ខេត្ត-ក្រុង តាមរយៈការបណ្តុះបណ្តាលដ៏ទូលំទូលាយមួយ និងកម្មវិធីអភិវឌ្ឍន៍ជំនាញ ដោយការបញ្ចប់ការរៀបចំសេចក្តីណែនាំសវនកម្មផ្ទៃក្នុង ឯកសារសវនកម្ម ព្រមទាំងពង្រឹងនាយកដ្ឋានសវនកម្មផ្ទៃក្នុង ។